# លិខិតពីតេហ្សេ

# Letter From Taize

Nº 274 Special Edition Khmer Letter 2012

## ដំណើរឆ្ពោះទៅរកការរួបរួមគ្នាជាធ្លុងតែមួយ/Towards a New Solidarity

ដើម្បីធ្វើអោយកើតមាននូវការរួបរួមគ្នាជាធ្លុងតែមួយក្នុងចំណោមមនុស្សទាំងអស់ គឺត្រូវការលើកទឹកចិត្តអោយ មានការរួបរួមគ្នានូវគ្រប់កំរិតទាំងអស់ *ក្នុងក្រុមគ្រួសារ, គ្រប់សហគមន៍, គ្រប់កន្លែងទីប្រជុំជន និងតាមភូមិ ហើយរវាងប្រទេសទាំងអស់ និងទ្វីបទាំងអស់ក្នុងពិភពលោក។*

ម្យ៉ាងវិញទៀតយើងត្រូវស្វែងយល់អំពីទំងន់នៃការឈឺចាប់ និងគ្រោះថ្នាក់មួយចំនួនដែលជាបន្ទុករបស់មនុស្ស និងពិភពលោកទាំងមូល ដែលយើងមិនចង់ធ្វើអោយវាស្ថិតក្នុងភាពភ័យក្លាច និងការបោះបង់ចោលទេ។ ហើយលើសពីនេះទៅទៀតការគំរាមកំហែងដោយភាពមិនទុកចិត្តគឺជារើយៗមិនអាចអោយមនុស្សមានសេចក្តីសង្ឃឹមបានឡើយ។ បញ្ហានៃផលលំបាកសេដ្ឋកិច្ចគឺកំពុងកើនឡើងយ៉ាងគំហុកនិងជាបន្ទុកយ៉ាងធ្ងន់ធ្ងរ ហើយពេលខ្លះភាពស្មុកស្មាញដ៏លើសលប់ក៏បានកើតមានក្នុងសង្គមជាច្រើន លើសពីនេះក៏កើតមាននូវគ្រោះមហន្តរាយពីធម្មជាតិដែលធ្វើអោយមនុស្សមានភាពតែលតោល និងទាំងអស់នេះណែនាំអោយយើងមានភាពទោទន់ទៅរកពន្លកនៃសេចក្តីសង្ឃឹមដែរ។

ដើម្បីបង្កើតទំរង់ថ្មីនៃការរួបរួមគ្នាជាធ្លុងតែមួយ៖ តើពេលវេលាអាចជាអ្នកបង្កើតនូវការខិតខំប្រឹងប្រែងដើម្បីលាតត្រដាងនូវការទុកចិត្ត? គឺមិនមែនទេ, មនុស្សជាអ្នកធ្វើ ហើយសង្គមគឺមិនអាចរស់បានទេប្រសិនបើគ្មានការទុកចិត្ត។

*នៅពេលទំនុកចិត្តត្រូវបានគេក្បត់ ពេលនោះរបួសគឺបង្កប់ទុកយ៉ាងជ្រៅក្នុងដួងចិត្ត។*

ការទុកចិត្តគឺមិនមែនខ្ជាក់ហើយងាយស្រួលបោកប្រាស់នោះទេ ហើយវាក៏មិនមែនជាពាក្យងាយស្រួលមួយដែរ សំរាប់និយាយក្នុងទំនាក់ទំនង។ វាគឺជាលទ្ធផលនៃជំរើសមួយ, ជាផលផ្លែនៃភាពតាន់តឹងខាងក្នុង ហើយពីមួយថ្ងៃទៅមួយថ្ងៃយើងទាំងអស់គ្នាគឺត្រូវបានគេអញ្ជើញ *អោយចាក់ចេញពីសេចក្តីបារម្មណ៍ឆ្ពោះទៅរកការទុកចិត្ត។*

## ការជឿទុកចិត្តក្នុងចំណោមមនុស្ស/Trust Among Human Beings

ទោះបីជាយ៉ាងណា ការបើកផ្លូវដើម្បីឆ្លើយតបទៅនឹងសេចក្តីទុកចិត្តសំរាប់តំរូវការបន្ទាន់ណាមួយ គឺធ្វើអោយការទំនាក់ទំនងកាន់តែមានភាពងាយស្រួលជាង ពីព្រោះមនុស្សយើងក្នុងសង្គមបច្ចុប្បន្នបាន មានការបែងចែកតាមផ្នែកនិមួយៗនៃក្រុមមនុស្ស។ ការហុំព័ទ្ធគំពែងសំរាប់រស់នៅមិនមែនសំរាប់តែ មនុស្ស និងទ្វីបប៉ុណ្ណោះទេ ប៉ុន្តែគឺនៅក្នុងយើងដែរ មិនត្រឹមតែប៉ុណ្ណោះគឺនៅក្នុងបេះដូងមនុស្សម្នាក់ៗ ហេតុនេះហើយសុំគិតអំពីការប្រកាន់ពូជសាសន៍ រវាងជនជាតិផ្សេងៗគ្នា និងគិតអំពីជនអន្តោប្រវេសន្ត ។ ពេលខ្លះវាហាក់ដូចជានៅជិតបំផុត ហើយពេលខ្លះវាហាក់ដូចជាសែនឆ្ងាយ ជាក់ស្តែងសាសនាជាច្រើន គឺនៅតែមានគំនិតអគតិចំពោះគ្នានិងគ្នា ក្នុងនោះគ្រីស្តបរិស័ទខ្លួនឯងគឺត្រូវបានបែងចែកតាមចំនួនច្រើន ផ្សេងៗគ្នាសំរាប់ហៅឈ្មោះរបស់ខ្លួន។ *ដូច្នេះសន្តិភាពនៃពិភពលោកគឺចាប់ផ្តើមពីក្នុងបេះដូងរបស់យើង ម្នាក់ៗ។*

ដើម្បីចាប់ផ្តើមនូវការរួបរួមគ្នាជាផ្លូងតែមួយគឺច្បាស់ណាស់យើងត្រូវមានទំនាក់ទំនងជាមួយអ្នក ដទៃផ្សេងទៀត មានពេលខ្លះយើងគ្មានអ្វីទាំងអស់ ដោយគ្រាន់តែស្តាប់ និងព្យាយាមយល់អំពីបុរស ឬ ស្រ្តីដែលមិនបានគិតដូចជាយើង ពេលនោះស្ថានភាពដែលនៅស្ងៀមនិងអាចផ្លាស់ប្តូបាន។

សូមយើងព្យាយាម ហើយយកចិត្តទុកដាក់ចំពោះមនុស្សដែលខ្សោយបំផុត, ចំពោះអស់អ្នកដែល ស្វែងរកការងារមិនបាន......ដោយការយកចិត្តទុកដាក់របស់យើងចំពោះអ្នកក្រីក្របំផុតក៏អាចបង្ហាញពីការ ចូលរួមពាក់ព័ន្ធក្នុងទំរង់នៃសកម្មភាពរបស់សង្គមដែរ។ មួយវិញទៀតដែលស្ថិតក្នុងកំរិតខ្ពស់ជាងនោះ គឺ អាកប្បកិរិយាមួយដែលបង្ហាញពីចិត្តទូលាយដល់មនុស្សទាំងឡាយ, ចំពោះអ្នកដែលនៅជិតយើង និងអ្នក ក្រីក្រដែលត្រូវការយើងជាចាំបាច់។

នៅក្នុងរូបភាពនៃភាពក្រីក្រ និងអយុត្តិធម៌ គឺអ្នកខ្លះបញ្ចប់ស្ថានភាពដោយការបំបះបំបោ ឬក៏ម្យ៉ាង ទៀតក្នុងគោលបំណងហឹង្សា *ក៏ប៉ុន្តែអំពើហឹង្សាមិនអាចផ្លាស់ប្តូសង្គមបានទេ* ផ្ទុយទៅវិញយើងត្រូវស្តាប់ នូវការបង្ហាញពីភាពឈឺចាប់របស់យុវជនដើម្បីក្តាប់អោយបាននូវអ្វីដែលជាមូលដ្ឋានគ្រិះនៃមូលហេតុ។

សន្ទុះដើម្បីឆ្ពោះទៅកាន់ការរួបរួមគ្នាជាផ្លូងតែមួយគឺត្រូវបានគេរក្សាទុកនៅក្នុងជំនឿយ៉ាងជ្រាល ជ្រៅ ដែលតម្រូវអោយមានការចែករំលែក ហើយការចែករំលែកនេះគឺជាអំណាចមួយដែលណែនាំអោយ

រួបរួមគ្នាក្នុងចំណោមអ្នកជឿគ្រប់សាសនាទាំងអស់ និងម្យ៉ាងវិញទៀតក៏ជាសញ្ញាល្អរវាងអ្នកដែលមិនជឿ និងអ្នកដែលមានជំនឿយ៉ាងមុតមាំ។

## *ការជឿទុកចិត្តក្នុងព្រះជាម្ចាស់/Trust in GOD*

ការរួបរួមគ្នាជាផ្លូវតែមួយក្នុងចំណោមមនុស្ស គឺយើងអាចរកឃើញបានក្នុងវត្តមានរបស់ព្រះជាម្ចាស់ ហើយបន្ថែមលើនេះទៀតការជឿទុកចិត្តលើព្រះជាម្ចាស់គឺជារឿយៗកើតមាននូវសំណួរជាប្រចាំ។ មានអ្នកដែលដើរតាមព្រះអង្គជាច្រើននាក់ មានបទពិសោធន៍អវិជ្ជមាននេះក្នុងកន្លែងធ្វើការ ឬកន្លែងសិក្សារបស់ពួកគេ ជូនពេលខ្លះគឺក្នុងគ្រួសាររបស់ពួកគេផ្ទាល់តែម្តង។

មានមនុស្សជាច្រើនដែលមិនអាចជឿលើព្រះជាម្ចាស់ ដោយទោះបីជាព្រះអង្គស្រលាញ់ពួកគេខ្លាំងប៉ុណ្ណាក៏ដោយ ហើយម្យ៉ាងវិញទៀតមានអ្នកខ្លះបានបង្ហាញពីភាពស្មោះត្រង់របស់ខ្លួនថា តើគេអាចដឹងអ្វីខ្លះប្រសិនបើគេជឿលើព្រះជាម្ចាស់?

*បច្ចុប្បន្ននេះជំនឿបានលេចចេញឡើងក្នុងភាពប្រថុយប្រថានមួយ គឺភាពប្រថុយប្រថានក្នុងការទុកចិត្តទាំងស្រុង។* ជំនឿមិនមែនមានន័យថាជាលេខរៀងទីមួយនោះទេ ប៉ុន្តែតំបូងគឺការប្រកាន់ភ្ជាប់នូវភាពពិត ដែលជាការទំនាក់ទំនងផ្ទាល់ជាមួយព្រះជាម្ចាស់ ហើយទំនាក់ទំនងនេះអាចហៅយើងអោយវិលចូលទៅក្នុងពន្លឺនៃព្រះអង្គផ្ទាល់តែម្តង។ លើសពីនេះទៅទៀតនាំអោយយើងធ្វើតាម ឬក៏បត់បែនខ្លួនរបស់យើងក្នុងជំនឿយ៉ាងពិតប្រាកដ។ *អស់អ្នកដែលបានទទួលជំនឿពីព្រះជាម្ចាស់ គឺធ្វើអោយយើងមានសេរីភាព គឺសេរីភាពពីសេចក្តីភ័យខ្លាច សេរីភាពក្នុងការរស់នៅសំរាប់ជីវិតយើងផ្ទាល់។*

មនុស្សទាំងអស់លើពិភពលោកក្នុងគ្រប់អរិយធម៌ គឺបានយល់ឃើញថា កាលណាការជឿទុកចិត្តលើព្រះជាម្ចាស់កាន់តែកើនឡើង ដួងចិត្តរបស់យើងក៏កាន់តែបើកទូលាយដល់មនុស្សគ្រប់គ្នា។ ប៉ុន្តែដួងចិត្តរបស់យើងម្នាក់ៗក៏ទទួលស្វាគមន៍នូវបច្ចេកវិទ្យា និងបច្ចេកទេសទំនើបៗជាច្រើនដែលវាអាចធ្វើអោយយើងធូស្រាលពីការឈឺចាប់និងអនុញ្ញាតអោយសង្គមមានភាពរីកចំរើនដែរ។ ប្រៀបដូចជាព្រះអាទិត្យ គឺព្រះជាម្ចាស់ធ្វើអោយយើងស្រវាំងភ្នែកពេលក្រឡេកមើលវា ប៉ុន្តែព្រះយេស៊ូបានអនុញ្ញាតអោយពន្លឺរបស់ព្រះជាម្ចាស់ចាំងចូលក្នុងជីវិតរបស់ព្រះអង្គទាំងស្រុង។ ក្នុងព្រះគម្ពីរទាំងមូលបានណែនាំយើង

ឆ្ពោះទៅកាន់សេចក្តីពិត ហើយជាក់ស្តែងដែលថាវត្តមានរបស់ព្រះជាម្ចាស់គឺវិសេសវិសាស ឧត្តុងឧត្តម ណាស់ក្នុងជីវិតយើងម្នាក់ៗ ដោយព្រះអង្គនិយាយមកកាន់យើងនូវភាសាដែលងាយយល់ជាទីបំផុត។

*តើអ្វីជាទីសម្គាល់អំពីជំនឿរបស់គ្រីស្តបរិស័ទ?* គឺព្រះយេស៊ូផ្ទាល់ ហើយនឹងទំនាក់ទំនងអស់កល ជានិច្ចរបស់យើងជាមួយព្រះអង្គ។ ចម្លើយនេះហើយគឺធ្វើអោយយើងយល់ដឹងអំពីសំណួរខាងលើ ដោយ មិនចេះចប់។

## ការរួមគ្នាក្នុងអង្គព្រះគ្រីស្ត/The Christ of COMMUNION

យើងទាំងអស់គ្នាជាបូជនីយជន និងជាអ្នកដើរតាមព្រះគ្រីស្ត បន្ទាប់ពីយើងទាំងអស់គ្នា បានជួប សេចក្តីពិតដែលជាព្រះគ្រីស្តផ្ទាល់។ ការមានជំនឿលើព្រះគ្រីស្តមិនត្រឹមតែ យើងបានជួបព្រះភក្រ្ត ព្រះអង្គផ្ទាល់នោះទេ តែយើងបានទទួលព្រះអង្គ ដែលជាសេចក្តីពិតចូលក្នុងជីវិតរបស់យើង ដោយ ចាក់ឫសយ៉ាងរឹងមាំក្នុងយើង និង នាំអោយយើងហ៊ានប្រកាសសេចក្តីពិតនោះក្នុងជីវិតយើងម្នាក់ៗ ។ របៀបដ៏ថ្មីនិងដ៏អស្ចារ្យបំផុត ដែលព្រះអង្គបានធ្វើសំរាប់យើង នោះគឺ ព្រះយេស៊ូគ្រីស្ត ដែលជាបុត្រ ដ៏ជាទី ស្រលាញ់របស់ព្រះជាម្ចាស់បានបន្ទាបខ្លួនសុខចិត្តកើតជាមនុស្សដ៏សាមញ្ញ និងព្រមបូជាព្រះជន្មព្រះអង្គ ផ្ទាល់ ដើម្បីសង្គ្រោះយើងទាំងអស់គ្នា ។ ព្រះយេស៊ូដែលមានឋានៈស្មើនឹងព្រះជាម្ចាស់ បានសុខចិត្តលះ បង់ឋានៈដ៏ខ្ពង់ខ្ពស់ មកកើតជា មនុស្សដ៏សាមញ្ញ ដែលមានសាច់មានឈាមដូចមនុស្សសុទ្ធសាត ហើយព្រះជាម្ចាស់បានសំដែងសិរីរុងរឿង និងការអស្ចារ្យរបស់ព្រះអង្គតាមរយៈព្រះយេស៊ូ ដែលកើត ជាមនុស្សដើម្បី អោយមនុស្សលោកមានជំនឿលើព្រះបិតាដែលជាព្រះជាម្ចាស់។ ដោយសារការអស្ចារ្យ នេះធ្វើអោយយើងម្នាក់ៗមានជំនឿកាន់តែរឹងមាំ និង មានសេចក្តីសង្ឃឹមឡើងវិញ ព្រមទាំងធ្វើអោយ

ពិភពលោករបស់យើងមានការកែប្រែដោយសារតែដំណឹងល្អដែលមកពីព្រះយេស៊ូគ្រីស្ត ។ ព្រះគ្រីស្ត បានធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ ដោយសុខចិត្តបូជាព្រះជន្មព្រះអង្គផ្ទាល់នៅលើឈើឆ្កាង ដើម្បី បង្ហាញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក និងដើម្បីបំផ្លាញសេចក្តីអាក្រក់ទាំង ឡាយដែលមាននៅក្នុងពិភពលោក ។ ដោយឈើឆ្កាងទ្រង់បានឈ្នះអំពើបាបនិងសេចក្តីអាក្រក់ទាំង ឡាយ ។ បើទោះបីលក្ខណៈនៃការរងទុក្ខលំបាកមិនសមនឹងព្រះអង្គទទួល និងមិនមានភាពយុត្តិធម៌ ក៏ដោយ ក៏ព្រះអង្គនៅតែមានជំនឿ និងទុកចិត្តលើព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រកា មានអំណាច

លើសេចក្តីអាក្រក់ទាំងឡាយ និង ដោយការបូជាព្រះជន្មរបស់ព្រះយេស៊ូ បានធ្វើអោយព្រះអង្គឈ្នះសេចក្តីស្លាប់ ។

ការរងទុក្ខលំបាកដ៏សែនអាម៉ាស់របស់ព្រះគ្រីស្តនៅលើឈើឆ្កាង រហូតដល់សោយទិវង្គត គឺដើម្បីបង្ហាញសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះអង្គចំពោះមនុស្សលោក ។ ព្រះជាម្ចាស់បានប្រោសព្រះគ្រីស្ត អោយមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបានឈ្នះសេចក្តីស្លាប់ ហើយព្រះអង្គយាងមកវិញនៅថ្ងៃទីបីព្រមទាំងប្រទាននូវព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ មកគង់ក្នុងជីវិតយើងម្នាក់ៗ និង តាមរយះព្រះអង្គធ្វើអោយយើងមានទំនាក់ទំនងផ្ទាល់ជាមួយព្រះបិតា ។ យើងមានជំនឿដោយសារតែព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ ហើយព្រះអង្គបានបង្ហាញខ្លួន នៅក្នុងចំណោមយើង។ ដូច្នេះសូមអោយយើងទាំងអស់គ្នាបើកភ្នែកមើលព្រះភក្រ្តព្រះអង្គ និង កែប្រែចិត្តគំនិតដោយសុខចិត្តជឿ ព្រមទាំងផ្ញើរជីវិតលើព្រះអង្គ ។ នៅពេលយើងសំឡឹងមើល ពន្លឺរបស់ព្រះគ្រីស្តនៅក្នុងការអធិដ្ឋាន បន្តិចម្តងៗពន្លឺនោះបានចូលទៅក្នុងយើងម្នាក់ៗ ។ និងដោយសារពន្លឺនេះហើយ ធ្វើអោយយើងស្គាល់តំលៃនៃជីវិតរស់នៅរបស់យើងសព្វថ្ងៃ ។ សេចក្តីអាក្រក់ និងភាពងងឹតរបស់យើង មិនអាចអូសទាញយើងបានទៀតទេ ផ្ទុយទៅវិញ ព្រះវិញ្ញាណដ៏វិសុទ្ធគឺព្រះគ្រីស្តផ្ទាល់ដែលជាពន្លឺ បំភ្លឺជីវិតរបស់យើង និងការពារយើងអោយ រួចពីសេចក្តីងងឹត ។ ការអធិដ្ឋានបានធ្វើអោយយើងមាចិត្តថ្លើមតែមួយនិងរួបរួមគ្នាជាធ្លុងតែយ ក្នុងអង្គព្រះគ្រីស្ត។ ដូចនាង ម៉ារីម៉ាដាឡាស ដែលបានក្រោកពីព្រលឹមទៅផ្នូរព្រះយេស៊ូ ហើយបានឃើញព្រះអង្គមានព្រះជន្មរស់ឡើងវិញ ដូច្នេះតាមរយៈហេតុការណ៏នេះ យើងទាំងអស់ត្រូវតែប្រកាសដំណឹងល្អទៅបងប្អូនឯទៀតៗអោយបានដឹង ។ បេសកកម្មព្រះសហាគមន៏ គឺដើម្បីប្រមែប្រមូលបងប្អូនទាំងប្រុស ទាំងស្រីទាំងក្មេងទាំងចាស់គ្រប់ភាសា គ្រប់អរិយធម៌ គ្រប់ជាតិសាសន៏ និង តំបន់ដាច់ស្រយាលនៃផែនដីអោយមកចូលរួមជាមហាគ្រួសារតែមួយក្នុងអង្គព្រះគ្រីស្ត ។ ពិតមែនព្រះសហាគមន៏គឺជាសញ្ញាបញ្ជាក់បង្ហាញអំពីសេចក្តីដែលបានចែងដ៏ពិតប្រាកដនៅក្នុងព្រះគម្ពីរ វាគឺជារូបការព្រះគ្រីស្តដែលមានព្រះជន្មគង់នៅតាមរយះព្រះវិញ្ញាណដ៏វិសុទ្ធ ហើយវាគឺកន្លែងដែលបានបង្ហាញវត្តមានព្រះកាយព្រះគ្រីស្ត យ៉ាងពិតប្រាកដ សំរាប់យើងម្នាក់ៗ។ នៅពេលព្រះសហាគមន៏ ចេះស្តាប់គ្នាទៅវិញទៅមក ចេះជួយសំរាលទុក្ខគ្នាទៅវិញទៅមក ចេះលើកលែងទោសអោយគ្នាទៅវិញទៅមកនោះ វាបានក្លាយជាកន្លែងមួយដែលមានពន្លឺយ៉ាងត្រចះត្រចង់ ពោរពេញដោយសេចក្តីស្រឡាញ់ សេចក្តីមេត្តាករុណា សន្តោសប្រណី ចិត្តបរិសុទ្ធ និង

ការគិតពិចារណាត្រូវ ដែលទាំងអស់នេះកើតមកបានដោយសារការមានព្រះជន្មគង់រស់ឡើងវិញរបស់ព្រះយេស៊ូ ហើយទ្រង់គង់ក្នុងយើងរាល់គ្នា ។

ព្រះគ្រីស្តបានធ្វើអោយយើងមានសេរីភាព ព្រះអង្គរំលាយនូវរបងវណ្ណៈ ឋានៈខ្ពង់ទាប អ្នកមាន អ្នកក្ររួចផុតពីការជិះជាន់សង្កត់សង្កិន មើលងាយមើលថោកផ្សេងៗ ដោយព្រះសហាគមន៍ដែលមានវត្តមានព្រះគ្រីស្តធ្វើអោយទទួលជំនឿនៃសេចក្តីពិតដ៏ត្រឹមត្រូវមួយដើម្បីបំភ្លឺនៅក្នុងដំណើរជីវិតយើង និង ក្នុងដួងចិត្តយើងរាល់គ្នា ។

## ធ្វើជាអំបិលសំរាប់ពិភពលោក/*Trying to be SALT OF THE EARTH*

ព្រះគ្រីស្តយាងមកមិនមែនអោយយើងក្លាយជាគ្រីស្តបរិស័ទដាច់លែកពីគេនោះទេ តែផ្ទុយទៅវិញព្រះអង្គចាត់យើងរាល់គ្នាអោយទៅ ក្នុងពិភពលោក ដោយធ្វើជាមេដំបែនៃសេចក្តីពិត និងកសាងសន្តិភាពសំរាប់មនុស្សទាំងអស់ ។ ការរួបរួមក្នុងចំណោមគ្រីស្តបរិស័ទវាមិនស្តែងចេញជាលទ្ធផលដោយឯកឯងបាននោះទេ តែវាអាចកើតឡើងដោយមានសញ្ញាមួយនៅក្នុងចំណោយយើងរាល់គ្នាដោយសារយើងរាល់គ្នាគឺជាអំបិលសំរាប់ពិភពលោក។ ដោយព្រះគ្រីស្តសោយទិវង្គត និង មានព្រះជន្មរស់ឡើងវិញបានធ្វើមានការរួបរួមគ្នាឡើងវិញ រវាងមនុស្សទាំងអស់ ។ ដោយសារព្រះគ្រីស្ត មនុស្សឈប់បាក់បែងគ្នាហែកហួរគ្នា ព្រះអង្គ ធ្វើអោយយើងក្លាយជាមហាគ្រួសារតែមួយ ហើយព្រះអង្គបានអោយយើងមានទំនាក់ទំនងសារជាថ្មីជាមួយព្រះជាម្ចាស់ ព្រះអង្គក៏បានអោយយើងមានទំនាក់ទំនងសារជាថ្មីជាមួយគ្នាទៅវិញទៅមកដែរ ។ ផ្ទុយទៅវិញបើយើងជាអំបិលបាត់ជាតិប្រៃហើយនោះ តើគេយកទៅធ្វើអ្វីកើតក្រៅពីបោះចោលទៅខាងក្រៅ និងមនុស្សដើរជាន់ប៉ុណ្ណោះ ។ ជាពិសេស តើយើងអាចមានឥទ្ធិពលអ្វីបានក្នុងការបង្កើតសន្តិភាព បើយើងមិនមានជាតិប្រៃសោះនោះ? បងប្អូនជាទីស្រឡាញ់ យើងកំពុងតែស្ថិតនៅពេលវេលាយ៉ាងពិសេសដែលយើងនឹងទទួលសារនៃសេចក្តីស្រឡាញ់ និង សន្តិភាពដែលមកពីព្រះជាម្ចាស់ ។ តាមរយៈសារនេះ ព្រះជាម្ចាស់នឹងលប់បំបាត់នូវភាពភ័ណច្រឡំ និងការយល់ខុសរបស់យើងហើយប្រទានមកវិញនូវ ពន្លឺដ៏ត្រចះត្រចង់អោយយើងវិញ ។ ដើម្បីអោយយើងអាចបង្ហាញជំនឿដូចកាលដែលយើងទើបតែ ទទួលកំលាំងមកពីព្រះអង្គពេលយើងបានទទួលពិធីជ្រមុជទឹក។

តើយើងធ្លាប់គិតថា យើងនឹងអាចធ្វើអ្វីដែលអស្ចារ្យដោយខ្លួនឯងរឺទេ? តើយើងធ្លាប់ដឹង ធ្លាប់ឃើញអ្នកណាដែលធ្វើដំណើរនៅក្នុងជីវិតរបស់ពួកគេដោយគ្មានជំនឿសោះរឺទេ? តើអ្នកណាដែលអាចស្វែងរកសេចក្តីពិត ដោយមិនប្រើបេះដូង និង ជំនឿរបស់ពួកគេ ?

នៅក្នុងការព្យាយាមបង្កើតនូវទំរងនៃសង្គមថ្មីមួយ ដែលមានការរួបរួម និង ពោរពេញដោយសេចក្តីពិតវាត្រូវតែអាចធ្វើទៅបានដោយមិនមានការវិនិច្ឆ័យ។ នៅពេលយើងគិតថា យើងមានគ្រប់អ្វីៗទាំងអស់ហើយ ។ ដូច្នេះតើយើងនឹងគួរតែធ្វើអ្វីបន្តទៀត? យើងមិនអាចនិយាយថាអ្វីដែលយើងមានពេញលក្ខណ:នោះទេ ។

ដែលក្នុងខណ:មនុស្សឯទៀតកំពុងតែស្វែងរក និងចាត់ទុកសេចក្តីស្រឡាញ់ដែលមកពីព្រះជាម្ចាស់ប្រសើរជាង ។ តើយើងចាត់ទុក ថា សេចក្តីស្រឡាញ់ពិតជាសំខាន់មែនរឺទេ សំរាប់យើងម្នាក់ៗ ?